វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តិប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ២៨ ខែ ធ្នូ ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- អ្នកសេដ្ឋកិច្ចនៅកម្ពុជា ផ្តល់យោបល់អោយមានការកែសម្រួលលើការចុះបញ្ជីអាជីវកម្ម
- វេទិកាយុវជនអាស៊ាន-ចិន ប្រមូលផ្តុំសហគ្រិនអោយមានការជួបជុំគ្នា
- បញ្ហាសំខាន់ៗបី បង្ហាញពីការធ្លាក់ចុះសេដ្ឋកិច្ចអាមេរិកនាពេលខាងមុខ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### អ្នកសេដ្ឋកិច្ចនៅកម្ពុជា ផ្តល់យោបល់អោយមានការកែសម្រួលលើការចុះបញ្ជីអាជីវកម្ម

យោងតាមអ្នកជំនាញដែលមកពីធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានថ្លែងនៅក្នុងសន្និសីទស្តីពី ការពង្រីកកំណើនសេដ្ឋកិច្ចកម្ពុជា ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជានាពេលថ្មីៗនេះ បានឲ្យដឹងថា ដើម្បីលើកទឹកចិត្តដល់សហគ្រិនភាព និងជម្រុញការវិនិយោគក្នុងស្រុក និងការច្នៃប្រឌិត ប្រទេសកម្ពុជាគួរតែកែម្រួលលើការចុះបញ្ជីអាជីវកម្ម ឲ្យមានតម្លៃទាប និងសេវាឆាប់រហ័សជាងមុន។

ការសម្រួលការចុះបញ្ជីអាជីវកម្ម រួមជាមួយនឹងការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់នូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច គឺជាគន្លឹះសំខាន់ដើម្បីលើកទឹកចិត្តដល់យុវជនកម្ពុជាក្នុងការចាប់ផ្តើមអាជីវ-កម្មផ្ទាល់ខ្លួន ក៏ដូចជាការបង្កើនចំនួនសហគ្រាសធុនតូច និងមធ្យម។

លោកជំទាវ ជា សិរី អគ្គនាយកនៃធនាគារជាតិ បានមានប្រសាសន៍ថា៖ បើទោះបីជាអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ៧,៧%សម្រាប់រយៈពេលពីរទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏កម្ពុជានៅតែមានមូលដ្ឋានកំណើនតូចចង្អៀតមួយ ដោយផ្តោតសំខាន់ថា កម្ពុជាត្រូវការធ្វើពិពិធកម្មដើម្បីជម្រុញឲ្យមានកំណើនប្រកបដោយចីរភាព។

### តារាងប្រចាំសប្តាហ៍៖ ការនាំចូលជ្រូករស់ពីថៃមកកម្ពុជាមានការធ្លាក់ចុះ

ស្ថិតិចុងក្រោយបំផុតរបស់នាយកដ្ឋានគយថៃបានបង្ហាញពីការធ្លាក់ចុះនូវការនាំចូលជ្រូករស់មកប្រទេសកម្ពុជាពីប្រទេសថៃ។

បន្ទាប់ពីការធ្លាក់ចុះជាទូទៅមក ការនាំចូលជ្រូករស់ពីប្រទេសថៃមកកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ រូបភាព នៅសប្តាហ៍នេះគឺបង្ហាញពីការធ្លាក់ចុះនៃការនាំចូល ដែលគិតជាទឹកប្រាក់ប្រមាណពី ៦៤ លានដុល្លារអាមេរិក នៅឆ្នាំ២០១៥ មក ៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧។

**តម្លៃនៃការនាំចូលជ្រូករស់ពីប្រទេសថៃមកកម្ពុជា (គិតជាពាន់ដុល្លារអាមេរិក)**




ប្រភព៖ នាយកដ្ឋានគយនៃប្រទេសថៃ

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### វេទិកាយុវជនអាស៊ាន-ចិន ប្រមូលផ្តុំសហគ្រិនអោយមានការជួបជុំគ្នា

វេទិកាសហគ្រិនវ័យក្មេងអាស៊ាន-ចិនលើកទី២(ACYEF) ត្រូវបាន ធ្វើឡើងនៅក្រុងសៀមរាបចាប់ពីថ្ងៃទី ១៧ ដល់១៨ ខែធ្នូ ឆ្នាំ២០១៨ ដោយមានការចូលរួមពីសហគ្រិនវ័យក្មេងប្រហែល១00នាក់ ពីតំបន់អាស៊ាន ក្រោមប្រធានបទ ″ការបង្កើតបច្ចេកវិទ្យា និងការច្នៃប្រឌិតសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម″។

សហគ្រិនដែលចូលរួម ជាតំណាង សមាគមអាជីវកម្មដែលមកពីតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសចិន។ វេទិកានេះបានផ្តល់ដល់អ្នកចូលរួមនូវឱកាសក្នុងការផ្លាស់ប្តូរទស្សនៈរបស់ពួកគេទៅលើគោលនយោបាយនិងការអនុវត្តល្អ ក្នុងការទទួលយកបច្ចេកវិទ្យានិងគំនិតច្នៃប្រឌិតថ្មីៗ ដើម្បីយកមកអនុវត្តនៅក្នុងអាជីវកម្មរបស់ខ្លួន។ យោងតាមសេចក្តីប្រកាសព័ត៌មាននៅលើគេហទំព័រលេខាធិការដ្ឋានអាស៊ាន បានឲ្យដឹងថា អ្នកចូលរួមក៏បានពិភាក្សាផងដែរអំពីវិធីសាស្រ្តក្នុងការកសាងសហគមន៍អាស៊ាន និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងអាស៊ាននិងចិន។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### បញ្ហាសំខាន់ៗបី បង្ហាញពីការធ្លាក់ចុះសេដ្ឋកិច្ចអាមេរិកនាពេលខាងមុខ

យោងតាមការវិភាគថ្មីមួយរបស់សាស្រ្តាចារ្យផ្នែកសេដ្ឋកិច្ច លោក Amitrajeet A. Batabyal នៃវិទ្យាស្ថានបច្ចេកវិទ្យា Rochester បានបង្ហាញពីបញ្ហាមួយចំនួនដែលអាចធ្វើឲ្យអាមេរិកជួបវិបត្តិសេដ្ឋកិច្ចនាពេលអនាគតដ៏ខ្លីខាងមុខនេះ។ ក្តីបារម្ភទីមួយ គឺជម្លោះពាណិជ្ជកម្មរវាង អាមេរិក និងចិន។ ការតម្លើងពន្ធ គឺបង្កើនថ្លៃដើមចំពោះអ្នកប្រើប្រាស់អាមេរិក ដែលជាហេតុនាំឲ្យតម្រូវការ មានការធ្លាក់ចុះ។ ការដាក់ពន្ធក៏អាចបង្អាក់នូវសកម្មភាពមួយចំនួនក្នុងទីក្រុងប៉េកាំងពីការបើកទូលាយរបស់ចិនអោយ ក្រុមហ៊ុនសហរដ្ឋអាមេរិកមានការចូលមកកាន់តែច្រើន។

បញ្ហាទីពីរ គឺភាពយឺតយ៉ាវនៃកំណើនសេដ្ឋកិច្ចពិភពលោកដោយសារតែសង្រ្គាមពាណិជ្ជកម្ម បានជះឥទ្ធិពលមិនត្រឹមតែទៅលើចិនប៉ុណ្ណោះទេ តែទៅលើប្រទេសដ៏ទៃទៀតដូចជាម៉ិកស៊ិកូ កាណាដា និងរដ្ឋដែលជាសមាជិកសហភាពអឺរ៉ុប ។ ប្រទេសចំនួន១៩ ដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ប្រាក់អឺរ៉ូស្ទើរតែមិនមានកំណើននៅក្នុងត្រីមាសចុងក្រោយ ដែលជាកម្រិតទាបបំផុតក្នុងរយៈពេល៤ឆ្នាំ។ កំណើនសេដ្ឋកិច្ចជាសកលយឺតមានន័យថា ការនាំចេញទំនិញដែលផលិតដោយអាមេរិកមានបរិមាណថយចុះ។

ក្តីបារម្ភទីបី គឺការភ័យខ្លាចនៃការបង្កើនអត្រាការប្រាក់បន្តិចម្តងៗរបស់ធនាគារកណ្តាលអាមេរិក ដែលអាចធ្វើឲ្យមានការរង្គោះរង្គើរដល់ទីផ្សារ និងវិនិយោគិន ដែលរួមចំណែកធ្វើឲ្យមានវិបត្តិសេដ្ឋកិច្ចដោយខ្លួនឯង នាពេលអនាគត។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

សប្តាហ៍ខាងមុខនេះមានភាពយឺតយ៉ាវសម្រាប់ការចេញផ្សាយទិន្នន័យដោយសារភ្នាក់ងារស្ថិតិកំពុងសម្រាកចូលរួមពិធីបុណ្យចូលឆ្នាំថ្មី។ យ៉ាងណាក៏ដោយ យើងនឹងទទួលបានព័ត៌មានខ្លះពីអតិផរណា នៅក្នុងប្រទេសកូរ៉េខាងត្បូង ឥណ្ឌូនេស៊ី ថៃ និងហ្វីលីពីន ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី ៣១ ខែធ្នូ</u>

- អត្រាអតិផរណា របស់កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- សន្ទស្សន៍ផលិតកម្ម PMI របស់ការិយាល័យស្ថិតិ (NBS) ចិន សម្រាប់ខែធ្នូ
- សន្ទស្សន៍មិនមែន ផលិតកម្ម PMI របស់ចិន សម្រាប់ខែធ្នូ
- សន្ទស្សន៍ថ្លៃអ្នកផលិត របស់ម៉ាឡេស៊ី សម្រាប់ខែវិច្ឆិកា

<u>ថ្ងៃអង្គារ ទី ០១ ខែមករា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ កូរ៉េខាងត្បូង សម្រាប់ខែធ្នូ

<u>ថ្ងៃពុធ ទី ០២ ខែមករា</u>

- ផ.ស.ស. របស់សឹង្ហបុរី សម្រាប់ការប៉ាន់ស្មានកម្រិតខ្ពស់ត្រីមាសទី៤ឆ្នាំ ២០១៨
- សន្ទស្សន៍ផលិតកម្ម PMI របស់ឥណ្ឌូនេស៊ី សម្រាប់ខែ ធ្នូ
- សន្ទស្សន៍ផលិតកម្ម PMI របស់ កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- សន្ទស្សន៍ផលិតកម្ម PMI Caixin របស់ចិន សម្រាប់ខែ ធ្នូ
- អត្រាអតិផរណា របស់ឥណ្ឌូនេស៊ី សម្រាប់ខែ ធ្នូ
- អត្រាអតិផរណា របស់ថៃ សម្រាប់ខែ ធ្នូ
- តុល្យភាពពាណិជ្ជកម្មរបស់ប្រ៊ុយណេ សម្រាប់ខែតុលា

<u>ថ្ងៃព្រហស្បត្តិ៍ ទី ០៣ ខែមករា</u>

- ទំនុកចិត្តអតិថិជនរបស់ថៃ សម្រាប់ខែធ្នូ
- ការទាមទាររបស់អ្នកគ្មានការងារធ្វើ នៅ អាមេរិក សម្រាប់ខែធ្នូ

<u>ថ្ងៃសុក្រ ទី ០៤ ខែមករា</u>

- ការលក់រថយន្តសរុបរបស់ អាមេរិក សម្រាប់ខែធ្នូ
- ប្រេងឆៅ API របស់អាមេរិក សម្រាប់ខែធ្នូ
- សន្ទស្សន៍ផលិតកម្ម PMI របស់ជប៉ុនសម្រាប់ខែធ្នូ
- អត្រាអតិផរណា របស់ហ្វីលីពីន សម្រាប់ខែធ្នូ
- តុល្យភាពនៃពាណិជ្ជកម្ម របស់ម៉ាឡេស៊ី សម្រាប់ខែវិច្ឆិកា
- ទំនុកចិត្តអាជីវកម្មរបស់ថៃ សម្រាប់ខែធ្នូ